# ក្រសួងផែនការ

## នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

## បទបង្ហាញស្តីពី

# នីតិវិធីសង្ខេបនៃអត្តសញ្ញាណគ្រួសារក្រីក្រ និង

# ការដាក់បញ្ចូលលក្រុមជនងាយរងគ្រោះទៅក្នុងដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ







*បង្ហាញដោយឯកឧត្តម កែវ អ៊ូលី ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ*

# មាតិកា

- គោលបំណងនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ
- សាវតាយន្តការនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ
- រចនាសម្ព័ន្ធ និងការពង្រឹងសមត្ថភាព
- ដំណើរអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅមូលដ្ឋាន
- លក្ខណៈវិនិច្ឆ័យ
- យន្តការដាក់បញ្ចូលលក្រុមបណ្ដាញជនងាយរងគ្រោះ
- លទ្ធផលបឋមទទួលបានពីការបញ្ចូលគ្រួសារផ្ទុកមេរោគអេដស៍ឆ្នាំ២០១៩
- បញ្ហាប្រឈម
- តំបន់គ្របដណ្ដប់ក្នុងផែនការឆ្នាំ ២០១៩-២០២១

## ❖ គោលបំណងនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ

- គឺជាការកំណត់រកឱ្យឃើញគ្រួសារក្រីក្រពិតប្រាកដ និងកម្រិតភាពក្រីក្ររបស់គ្រួសារ៖ ប្រើប្រាស់ទិន្នន័យដើម្បីផ្តល់សេវា និងជំនួយឱ្យចំគោលដៅដល់គ្រួសារក្រីក្រ និងសមាជិកនីមួយៗ ដើម្បីជួយពួកគាត់ឱ្យងើបផុតពីភាពក្រីក្រ ហើយការពារពួកគាត់ពីវិបត្តិចៃដន្យ ដែលអាចធ្វើឱ្យភាពក្រីក្ររបស់គាត់កាន់តែធ្ងន់ធ្ងរ។
- ដើម្បីកំណត់គ្រួសារក្រីក្រជាស្តង់ដាររួមមួយ៖ កាត់បន្ថយទិន្នន័យស្ទួនគ្នានៃការកំណត់គ្រួសារក្រីក្រតាមបណ្តាក្រសួងស្ថាប័នអង្គការសង្គមស៊ីវិល។
- កំណត់អត្រាភាពក្រីក្រ នៅតំបន់នានា៖ ទិន្នន័យអាចត្រូវប្រើប្រាស់ដើម្បីគណនាអត្រាប្រៀបធៀបកម្រិតភាពក្រីក្ររបស់ស្រុក ឃុំ និងភូមិនីមួយៗ ដើម្បីកំណត់តំបន់អាទិភាពសម្រាប់ផ្តល់សេវា និងជំនួយផ្សេងៗ ។

# សាវតានៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ

- នៅឆ្នាំ២០០៥៖ ក្រសួងផែនការដោយមានការជួយគាំទ្រពី ជីអាយហ្សិត (GIZ) បានបង្កើត និង អនុវត្តសាកល្បងនីតិវិធី"អត្តសញ្ញាណកម្មគ្រួសារក្រីក្រ" សម្រាប់តំបន់ជនបទ។ ហើយអនុវត្តជាផ្លូវការ នៅឆ្នាំ២០០៧។
- អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានអនុម័តក្នុងសម័យប្រជុំ គណៈរដ្ឋមន្រ្តីកាលពីថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១១ និងចុះហត្ថលេខាដោយ នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១
- នៅចុងឆ្នាំ២០១៦៖ ក្រសួងផែនការបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ និងបានអនុវត្តនីតិវិធីទីប្រជុំជន ជុំទី១ ដែលមានចំនួន ៩ រាជធានី/ខេត្ត៖ ភ្នំពេញ បាត់ដំបង កំពង់ឆ្នាំង កណ្តាល ព្រះវិហារ ពោធិ៍សាត់ រតនគិរី តាកែវ និងប៉ៃលិន។
- បច្ចុប្បន្នយើងបានអនុវត្ត ៨-៩ រាជធានី/ខេត្ត ក្នុងមួយឆ្នាំ និងបានធ្វើបច្ចុប្បន្នភាពរៀងរាល់៣ឆ្នាំម្តង។ ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្របានអនុវត្តស្របគ្នា ទាំងតំបន់ជនបទ និងតំបន់ទីប្រជុំជន។

# សាវតានៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ(ត)

- ស្របពេលដែល យើងបានធ្វើការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមជុំធម្មតាជាទៀងទាត់ ក៏មានគ្រួសារមួយចំនួន ខកខានក្នុងការចូលរួមធ្វើបច្ចុប្បន្នកម្ម និងគ្រួសារមួយចំនួនមានកំរិតជីវភាពធ្លាក់ក្នុងភាពក្រីក្រ ក្រោយពេលការធ្វើបច្ចុប្បន្នកម្ម។
- នៅចុងឆ្នាំ២០១៧៖ ក្រសួងផែនការបានរៀបចំនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ និងបានអនុវត្តសាកល្បងជាលក្ខណៈទ្រង់ទ្រាយតូច ក្នុងខេត្តចំនួន៣គឺបាត់ដំបង រតនគីរី និងត្បូងឃ្មុំ ដោយមានការជួយគាំទ្រពីអង្គការ ជីអាយហ្សិត (GIZ)។
- នៅឆ្នាំ២០២១នឹងអនុវត្តជាផ្លូវការនូវការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំដែលគ្របដណ្តប់លើរាជធានីនិងខេត្តចំនួន៩ មានរាជធានីភ្នំពេញ ខេត្តកំពង់ធំ ក្រចេះ ស្ទឹងត្រែង កំពង់ចាម សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ

# រចនាសម្ព័ន្ធ និងការបណ្តុះបណ្តាល

- រចនាសម្ព័ន្ធ៖ អនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងរចនាសម្ព័ន្ធសហគមន៍។

1. ក្រសួងផែនការ
2. មន្ទីរផែនការខេត្ត រាជធានី
3. ក្រុមសម្របសម្រួលក្រុង/ស្រុក
4. ក្រុមប្រឹក្សាឃុំ សង្កាត់, តំណាងគណៈកម្មាធិការ កសាងផែនការនិងថវិកា
5. ក្រុមតំណាងភូមិ (ដែលត្រូវបានជ្រើសរើសដោយអ្នកភូមិផ្ទាល់)

# រចនាសម្ព័ន្ធ និងការបណ្តុះបណ្តាល(ត)

❖ ការបណ្តុះបណ្តាល៖

**មន្ត្រីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**

| នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | ការតាមដាន និងត្រួតពិនិត្យ |
|---|---|

↓ *ថ្នាក់ខេត្ត*

**មន្ត្រីមន្ទីរផែនការខេត្ត និងក្រុមសម្របសម្រួលស្រុក**

| នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | ការតាមដាន និងត្រួតពិនិត្យ |
|---|---|

↓ *ថ្នាក់ស្រុក*

**ក្រុមតំណាង គ.ផ.ថ**

នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជំហានទី៣ (ការចងក្រងបញ្ជីគ្រួសារក្នុងភូមិ, ការប្រើប្រាស់បញ្ជីសំណួរ,...)

↓ *ថ្នាក់ឃុំ*

**ក្រុមតំណាងភូមិ**

អនុវត្តការចុះសម្ភាសន៍សាកល្បងនៅតាមភូមិជាក់ស្តែង

# ដំណើរអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

- ការចងក្រងបញ្ជីគ្រួសារសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ការសម្ភាសន៍គ្រួសារ និង ការពិនិត្យផ្ទៀងផ្ទាត់ដំណើរការសម្ភាសន៍
- ការរៀបចំបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- ការពិនិត្យបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- ការរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រ
- ការធ្វើសុពលភាពបញ្ជីព្រាងគ្រួសារក្រីក្រ
- ការរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ
- ការពិនិត្យ និងអនុលោមភាពបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ
- ការចេញលិខិតបញ្ជាក់អត្តសញ្ញាណគ្រួសារក្រីក្រ
- ការបញ្ចូលទិន្នន័យ ការថតរូបគ្រួសារក្រី និងការបញ្ចេញប័ណ្ណសមធម៌

# លក្ខណៈវិនិច្ឆ័យនៃការកំណត់គ្រួសារក្រីក្រ

❖ សំណួរដាក់ពិន្ទុ តំបន់ជនបទ

- ផ្ទះសម្បែង ដំបូល ជញ្ជាំង ផ្ទៃក្រឡាកំរាល ស្ថានភាពទូទៅនៃផ្ទះ
- ផ្ទៃដីធ្វើស្រែ ចំការ និងដាំដំណាំ គិតជាហិកតា(ភូមិស្ថិតនៅលើគោក)/ ឧបករណ៍នេសាទ (ភូមិស្ថិតនៅលើទឹក) ឬប្រភពចំណូលផ្សេងទៀតដូចជាស៊ីឈ្នួល ធ្វើការមានប្រាក់ខែ ឬមានអាជីវកម្ម
- ការចិញ្ចឹមសត្វ (រួមទាំងចិញ្ចឹមត្រីដើម្បីលក់)
- គ្រឿងអេឡិកត្រូនិក និងទ្រព្យសម្បត្តិមួយចំនួនទៀត
- មធ្យោបាយធ្វើដំណើរ (រួមទាំងទូកសម្រាប់ភូមិស្ថិតនៅលើទឹក)
- ជំពាក់ ឬបុលស្រូវអង្ករ (បង្ហាញសមត្ថភាពដើម្បីដោះស្រាយតម្រូវការស្បៀងអាហារ)
- សមាមាត្រនៃសមាជិកគ្រួសារក្នុងបន្ទុក ធៀបនឹងសមាជិកគ្រួសារដែលអាចរកចំណូលបាន

# លក្ខណៈវិនិច្ឆ័យនៃការកំណត់គ្រួសារក្រីក្រ (ត)

## សំណួរដាក់ពិន្ទុ តំបន់ទីប្រជុំជន

- ភូមិទីប្រជុំជន៖ គឺកំណត់លើភូមិណាមួយដែលមានគ្រួសារប្រកបរបរកសិកម្ម តិចជាង ៥០% ក្រៅពីភូមិប្រជុំជនដែលបានកំណត់នេះ នឹងត្រូវចាត់ទុកជាភូមិជនបទ។
- **សំណួរដាក់ពិន្ទុ៖** ផ្អែកលើលក្ខណវិនិច្ឆ័យនេះ ការប្រើប្រាស់នីតិវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រក៏មាន លក្ខណៈខុសគ្នាផងដែរ មានជាអាទិ៍៖
  - ✓ថ្លៃភ្លើង
  - ✓ទឹកស្អាត និងអនាម័យ
  - ✓ថ្លៃឈ្នួលផ្ទះ
  - ✓ចំណូល ចំណាយរបស់គ្រួសារ
  - ✓បំណុលរបស់គ្រួសារ
  - ✓ស្ថានភាពអប់រំរបស់សមាជិកគ្រួសារ
  - ✓ស្ថានភាពជំងឺ របួស និងពិការភាព

# លក្ខណៈវិនិច្ឆ័យនៃការកំណត់គ្រួសារក្រីក្រ (ត)

❖ **សំណួរមិនដាក់ពិន្ទុ - ស្ថានភាពពិសេស** សម្រាប់ពិភាក្សាដោយក្រុមតំណាងភូមិ

- បញ្ហា ឬវិបត្តិចៃដន្យដែលបណ្ដាលឱ្យគ្រួសារបាត់បង់ប្រាក់ចំណូល ខ្វះខាតស្បៀងអាហារ លក់ទ្រព្យសម្បត្តិ ឬខ្ចីលុយគេក្នុងរយៈពេល ១២ ខែកន្លងមក
- ចំនួនក្មេងដែលមានអាយុចាប់ពី ៦ ដល់១១ឆ្នាំ ដែលខកខាន ឬមិនបានចូលរៀនយ៉ាងតិច ១ខែ ក្នុងអំឡុងពេល១២ខែកន្លងមក
- ស្ថានភាពពិសេសរបស់គ្រួសារ (ពិការភាព ឈឺ ចាស់ជរា ស្ត្រីមេម៉ាយជាមេគ្រួសារ និង មានកូនតូចច្រើន គ្មានមនុស្សពេញវ័យ ។ល។)
- ស្ថានភាពផ្សេងទៀតដែលធ្វើឱ្យជីវភាពប្រសើរឡើង (ឧទា. ជំនួយ លុយកាក់ពីកូន ឬសាច់ញ្ញាតិ, ទើបតែលក់ដី)

# លក្ខណៈវិនិច្ឆ័យនៃការកំណត់គ្រួសារក្រីក្រ ( ត )

ចំណាត់ថ្នាក់ភាពក្រីក្រមានពីរ ៖

១

- ក្រកម្រិតទី ១ ( ទីទ័លក្រ )

២

- ក្រកម្រិតទី ២ ( ក្រ )

# ប្រវត្តិការដាក់បញ្ចូលក្រុមបណ្តាញជនងាយរងគ្រោះក្នុងដំណើរការកំណត់គ្រួសារក្រីក្រ

- នៅខែមិនា ឆ្នាំ២០១៦៖ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាគមអតីតយុទ្ធជនកម្ពុជា និងសមាគមអង្គការជនពិការ បានស្នើសុំក្រសួងផែនការដើម្បី ពិនិត្យ ពិចារណា ដាក់បញ្ចូលគ្រួសារផ្ទុកមេរោគអេដស៍ និងជនពិការ ទៅក្នុងបញ្ជីគ្រួសារក្រីក្រ

- ចាប់ពីឆ្នាំ២០១៧៖ អង្គការ UNDP និង UNAIDS បានសហការណ៍ជាមួយក្រសួងផែនការ ដើម្បីពិនិត្យ និងផ្តល់ឱកាសក្នុងការដាក់បញ្ចូលក្រុមបណ្តាញជនងាយរងគ្រោះ ក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# យន្តការដាក់បញ្ចូលក្រុមបណ្តាញជនងាយរងគ្រោះ

- សម្របសម្រួលឲ្យមានសមាសភាពក្រុមបណ្តាញជនងាយរងគ្រោះទៅក្នុងរចនាសម្ព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រគ្រប់កម្រិត។
- ក្រុមបណ្តាញជនងាយរងគ្រោះ មានតួនាទីជាអ្នកសង្កេតការណ៍ និងផ្តល់យោបល់ក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- កំណត់អាទិភាពចំពោះគ្រួសារស្ថិតនៅក្នុងបណ្តាញជនងាយរងគ្រោះទាំងអស់ មានដូចជា គ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ ជនពិការ ជនរស់នៅជាមួយគ្រឿងញៀន ជនស្រលាញ់ភេទដូចគ្នា និងជនបំរើកន្លែងសប្បាយ...។ល។ ដាក់បញ្ចូលសម្រាប់ការសម្ភាសន៍ និងពិនិត្យស្ថានភាពពិសេស
- សម្របសម្រួលក្នុងការស្វែងរកគ្រួសារងាយរងគ្រោះ ដើម្បីដាក់បញ្ចូលក្នុងបញ្ជីគ្រួសារក្នុងភូមិ និងគ្រួសារត្រូវសម្ភាសន៍
- សម្របសម្រួលក្នុងដំណើរការសម្ភាសន៍គ្រួសារងាយរងគ្រោះ
- ចូលរួមរៀបចំបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ ជាពិសេសពិនិត្យលើស្ថានភាពពិសេស របស់គ្រួសារដែលផ្តោតលើភាពងាយរងគ្រោះ ដែលក្រុមបណ្តាញជួបប្រទះ

# យន្តការដាក់បញ្ចូលលក្រុមបណ្តាញជនងាយរងគ្រោះ

- ចូលរួមក្នុងដំណើរការប្រជុំភូមិដើម្បីពិនិត្យបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ដែលជាយន្តការបែបប្រជាធិបតេយ្យ
- ជួយដោះស្រាយបញ្ហានានា ដែលអាចកើតឡើងដោយចៃដន្យ រវាងក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាមួយគ្រួសារងាយរងគ្រោះ តាមរយៈការប្រើប្រាស់ពាក្យសំដី មិនត្រឹមត្រូវ នឹងក្របខណ្ឌច្បាប់
- ចូលរួមការប្រជុំ តាមការអញ្ជើញពីប្រធានលេខាធិការដ្ឋាន ឬប្រធានក្រុមការងារក្នុងរចនាសម្ព័ន្ធណាមួយរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ចូលរួមតាមដានគ្រប់សកម្មភាពផ្សេងទៀត ដែលមានក្នុងនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ផ្សព្វផ្សាយអំពីពេលវេលា និងសកម្មភាពជាក់លាក់ នៃការអនុវត្ត អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់គ្រួសារងាយរងគ្រោះ។

# លទ្ធផលបឋមទទួលបានពីការបញ្ចូលគ្រួសារផ្ទុកមេរោគអេដស៍ឆ្នាំ២០១៩

ឧទាហរណ៍

- ខេត្តបាត់ដំបង៖ បានបញ្ចូលគ្រួសារដែលផ្ទុកមេរោគនៅឃុំរការ ចំនួន២១០គ្រួសារនិងនៅតំបន់ផ្សេងៗទៀតក៏បានណែនាំឱ្យដាក់បញ្ចូលផងដែរ
- ខេត្តកំពង់ឆ្នាំង៖បានបញ្ចូលគ្រួសារដែលផ្ទុកមេរោគអេដស៍ចំនួន ១៧៥គ្រួសារ
- ខេត្តតាកែវ៖បានបញ្ចូលគ្រួសារផ្ទុកមេរោគអេដស៍ចំនួន៥៨គ្រួសារ
- ខេត្តកណ្តាល៖បានបញ្ចូលគ្រួសារផ្ទុកមេរោគអេដស៍ចំនួន២ស្រុក ស្រុកស្អាង១៩៤គ្រួសារ និងក្រុងតាខ្មៅ២១១គ្រួសារ

## បញ្ហាប្រឈម

- ការសហការ និងការទំនាក់ទំនងរវាងក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមបណ្តាញហាក់នូវមានកម្រិត
- ក្រុមទាំងពីរនេះ ហាក់មិនទាន់បើកចិត្តទូលាយក្នុងការទទួលយកការងារដែលជម្រុញឲ្យមានការសហការគ្នា
- សមត្ថភាពនៃក្រុមការងាររបស់បណ្តាញ ហាក់នូវមានកម្រិតក្នុងការសន្ទនា និងសម្របសម្រួល
- មានការផ្លាស់ប្តូរសមាសភាពញឹកញាប់ ពិបាកទំនាក់ទំនង (ខេត្តខ្លះ)
- គ្មានទីកន្លែង និងស្នាក់ការច្បាស់លាស់ ដើម្បីទំនាក់ទំនង
- មិនមានពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមប្រជុំនានា និងតាមដានសកម្មភាព

## បញ្ហាប្រឈម

- មិនមានសមាសភាពគ្រប់គ្រាន់ សម្រាប់បញ្ចូលគ្រប់រចនាសម្ព័ន្ធ ជាពិសេស សមាជិកក្រុមតំណាងភូមិ
- បញ្ជីឈ្មោះគ្រួសារខ្លះដែលផ្តល់ឲ្យដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រកមិនឃើញនៅក្នុងភូមិ
- មានគ្រួសារមួយចំនួនគម្រាមប្តឹងក្រុមការងារ
- នៅមានការខ្វះខាតច្រើនសម្រាប់ក្រុមបណ្តាញជនងាយរងគ្រោះ ក្នុងការចូលរួម ដោយសារ កត្តាធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈ
- ការរៀបចំប្រជុំពិនិត្យការងារ និងដោះស្រាយបញ្ហាផ្សេងៗ មានតិចតួចបំផុត

# តំបន់គ្រប់ដណ្តប់ក្នុងផែនការឆ្នាំ ២០១៩-២០២១

| ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
|---|---|---|
| 1. បាត់ដំបង<br>2. កំពង់ឆ្នាំង<br>3. កណ្តាល<br>4. ព្រះវិហារ<br>5. ពោធិ៍សាត់<br>6. រតនគិរី<br>7. តាកែវ<br>8. ប៉ៃលិន | 1. កំពង់ស្ពឺ<br>2. កំពត<br>3. កោះកុង<br>4. មណ្ឌលគិរី<br>5. ព្រៃវែង<br>6. ព្រះសីហនុ<br>7. ស្វាយរៀង<br>8. កែប | 1. បន្ទាយមានជ័យ<br>2. កំពង់ចាម<br>3. ត្បូងឃ្មុំ<br>4. កំពង់ធំ<br>5. ក្រចេះ<br>6. ភ្នំពេញ<br>7. សៀមរាប<br>8. ស្ទឹងត្រែង<br>9. ឧត្តរមានជ័យ |

*ធ្វើបច្ចុប្បន្នកម្មរៀងរាល់ ៣ឆ្នាំម្តង*

# សូមអរគុណ